# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :.....៥០.....សសរ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតលេខាធិការដ្ឋាន របស់ការិយាល័យសន្តិសុខថ្នាក់កណ្តាល

## ការិយាល័យសន្តិសុខថ្នាក់កណ្តាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការអោយបង្កើតក្រសួងការពារជាតិ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី១៩ ខែមិនា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

-បានឃើញសេចក្តីសំរេចលេខ ៤៦សសរ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០១ ស្តីពីការបង្កើតគណៈបញ្ជាការការពារការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ហៅកាត់ថា "ការិយាល័យសន្តិសុខថ្នាក់កណ្តាល"

-បានឃើញសេចក្តីសំរេចលេខ ៤៧សសរ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០០១ ស្តីពី[illegible] សមាសភាពគណៈបញ្ជាការការពារការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់

-ផ្អែកតាមការចាំបាច់របស់ការិយាល័យសន្តិសុខថ្នាក់កណ្តាល ។

www.pheakdeylaw.com

## សំរេច

**ប្រការ១.**- ត្រូវបានបង្កើតលេខាធិការដ្ឋាន របស់ការិយាល័យសន្តិសុខថ្នាក់កណ្តាល ដែលមានសមាសភាព ដូចតទៅ :

| | | | |
|---|---|---|---|
| + ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ហុក ឡុងឌី** | អគ្គនាយកនគរបាលជាតិ | ប្រធាន |
| + ឯកឧត្តម ឧត្តមសេនីយ៍ឯក | **មាស សុផា** | អគ្គមេបញ្ជាការរង មេបញ្ជាការ កងទ័ពជើងគោក | អនុប្រធាន |
| + ឯកឧត្តម ឧត្តមសេនីយ៍ឯក | **សៅ សុខា** | មេបញ្ជាការកងរាជអាវុធហត្ថ លើផ្ទៃប្រទេស | សមាជិក |
| + ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ជា សារិន** | មេបញ្ជាការរងកងទ័ពជើងគោក | សមាជិក |
| + ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ជា តារា** | នាយសេនាធិការរងចំរុះ នាយកទីចាត់ការ កលយុទ្ធ | សមាជិក |
| + ឯកឧត្តម ឧត្តមសេនីយ៍ទោ | **យូ ស៊ុនឡុង** | ប្រធាននាយកដ្ឋានកណ្តាល សន្តិសុខ | សមាជិក |
| + ឯកឧត្តម ឧត្តមសេនីយ៍ទោ | **នេត្រ សារ៉ឿន** | ប្រធាននាយកដ្ឋានកណ្តាល នគរបាលយុត្តិធម៌ | សមាជិក |
| + ឯកឧត្តម ឧត្តមសេនីយ៍ទោ | **ហួត ឈាង** | នាយកទីចាត់ការ ការិយាល័យទី៣ កងទ័ពជើងគោក | សមាជិក |
| + លោក ឧត្តមសេនីយ៍ត្រី | **ឈឹម ច័ន្ទពណ៌** | មេបញ្ជាការរងកងរាជអាវុធហត្ថ លើផ្ទៃប្រទេស | សមាជិក |
| + លោក ឧត្តមសេនីយ៍ត្រី | **សៅ សារិន** | មេបញ្ជាការរងកងទ័ពជើងទឹក ប្រធានសេនាធិការ | សមាជិក |
| + លោក ឧត្តមសេនីយ៍ត្រី | **សេស នាគសេត្ថា** | មេបញ្ជាការរងកងទ័ពជើងអាកាស ប្រធានសេនាធិការ | សមាជិក |
| + លោក ឧត្តមសេនីយ៍ត្រី | **ម៉ៅ ច័ន្ទតារា** | ប្រធានសេនាធិការ អគ្គនាយកដ្ឋាននគរបាលជាតិ | សមាជិក |
| + លោក ឧត្តមសេនីយ៍ត្រី | **សុខ ផល** | ប្រធាននាយកដ្ឋានព័ត៌មានទូទៅ | សមាជិក |
| + លោក ឧត្តមសេនីយ៍ត្រី | **គន្ធ សំអឿន** | ប្រធាននាយកដ្ឋានប្រឆាំងភេរវកម្ម | សមាជិក |
| + លោក ឧត្តមសេនីយ៍ត្រី | **ឡេវ ស៊ុនឆៃ** | ប្រធាននាយកដ្ឋាននគរបាលព្រហ្មទ័ណ្ឌ | សមាជិក |

www.pheakdeylaw.com

+ឯកឧត្តម ឧត្តមសេនីយ៍ត្រី ទ័រន់ រដ្ឋា ប្រធាននាយកដ្ឋានបច្ចេកទេសវិទ្យាសាស្ត្រ សមាជិក

+ឯកឧត្តម នុត សាវអុន ទីប្រឹក្សាឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល សមាជិក

+លោក ប៊ូន លិមហេង ប្រធាននាយកដ្ឋានផ្គត់ផ្គង់ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

**ប្រការ២.**-លេខាធិការដ្ឋានមានភារកិច្ចដូចតទៅ :

-ជួយប្រធានការិយាល័យសន្តិសុខថ្នាក់កណ្តាល ក្នុងការផ្សព្វផ្សាយ និងតាមដានចាត់តាំងអនុវត្តផែនការការពារសន្តិសុខ សុវត្ថិភាពក្នុងដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

-ផ្សព្វផ្សាយគោលការណ៍ ផែនការផ្សេងៗរបស់ការិយាល័យសន្តិសុខថ្នាក់កណ្តាលជូនទៅការិយាល័យសន្តិសុខថ្នាក់ក្រោម ។

-ចាត់តាំងកំលាំង ដើម្បីប្រតិបត្តិការការពារការបោះឆ្នោតតាមគំរោងផែនការដែលបានកំណត់ ។

-ប្រមូលផ្តុំព័ត៌មានពីការិយាល័យសន្តិសុខថ្នាក់ក្រោម ដើម្បីរាយការណ៍ជូនប្រធានការិយាល័យសន្តិសុខថ្នាក់កណ្តាល ។

-ពិនិត្យដោះស្រាយរាល់ការវិវាទផ្សេងៗ ឬបណ្តឹងតវ៉ាពាក់ព័ន្ធដល់សន្តិសុខនៃការបោះឆ្នោត ធ្វើរបាយការណ៍ជូនការិយាល័យសន្តិសុខថ្នាក់កណ្តាលរៀងរាល់ ១៥ថ្ងៃម្តង ។

-រៀបចំកម្មវិធីប្រជុំ ធ្វើលិខិតអញ្ជើញគ្រប់សមាជិកការិយាល័យសន្តិសុខថ្នាក់កណ្តាលទាំងអស់ និងគ្រប់គ្រងឯកសារនានាតាមការសំរេចរបស់ប្រធានការិយាល័យសន្តិសុខថ្នាក់កណ្តាល ។

-ធ្វើគំរោងថវិកា ឧបករណ៍ សំភារៈ មធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ សំរាប់បំរើការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដាក់ជូនប្រធានការិយាល័យសន្តិសុខថ្នាក់កណ្តាលពិនិត្យ និងសំរេច ។

-ធ្វើរបាយការណ៍ចំណូលចំណាយថវិកា និងការប្រើប្រាស់ឧបករណ៍សំភារៈ និងមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទប្រចាំខែ ជូនការិយាល័យសន្តិសុខថ្នាក់កណ្តាលដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាល ។

**ប្រការ៣.**-លេខាធិការដ្ឋានមានសិទ្ធិបង្កើតក្រុមការងារ ដើម្បីជាជំនួយការតាមដានដឹកនាំបញ្ជា និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ ។

www.pheakdeylaw.com

- ប្រមូលផ្តុំចាត់ចែងប្រើប្រាស់សំភារៈ ឧបករណ៍ និង មធ្យោបាយដឹកជញ្ជូន គ្រប់ប្រភេទរបស់បណ្តាអង្គភាពផ្ទាល់ដែលមានស្រាប់ ដើម្បីបំរើដល់ប្រតិបត្តិការរក្សាសន្តិសុខសណ្តាប់ធ្នាប់អោយបានល្អប្រសើរក្នុងពេលដំណើរការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។
- ចាត់ចែងបើកផ្តល់ថវិកាបំប៉នជូនកំលាំងការពារតាមគោលដៅ និង ចាត់ចែងធ្វើគំរោងបែងចែក ឧបករណ៍ សំភារៈ មធ្យោបាយដឹកជញ្ជូនឱ្យបានសមស្របតាមមុខសញ្ញា និងគោលដៅចាំបាច់ ។

**ប្រការ៤**.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គនាយកនគរបាលជាតិ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងសាមីខ្លួនដែលមានឈ្មោះក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅភ្នំពេញ,ថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០១

**ជ.នាយករដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រី**

**និងជាប្រធានការិយាល័យសន្តិសុខថ្នាក់កណ្តាល**

**ស ខេង**

ចម្លងជូន :

- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី ស ខេង
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងសេដ្ឋកិច្ច-ហិរញ្ញវត្ថុ
- អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ
- អគ្គនាយកដ្ឋាននគរបាលជាតិ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស
- គ្រប់សាលាខេត្ត-ក្រុង
- ដូចក្នុងប្រការ១
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com